# **សេចក្តីជូនដំណឹង**

## ស្តីពីការជ្រើសរើសសិក្ខាកាមចូលរៀនវគ្គ បំពាក់បំប៉នជំនាញបន្ថែមផ្នែកថតភាពយន្ត

មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងទទួលការថតភាពយន្តនៅកម្ពុជា ឬ Cambodia Film Commission នឹងបើក **វគ្គបំពាក់បំប៉នជំនាញបន្ថែមផ្នែកថតភាពយន្ត “Cinematography”** ចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩ ខាងមុខនេះ ដែលបង្ហាត់បង្រៀនដោយ អ្នកដឹកនាំរឿង **លោក Bryan Norton** មកពីប្រទេសញ៉ូហ្សេឡែន។

កម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយរឿងនិទាន រឿងព្រេង រឿងប្រវត្តិសាស្រ្ត និងរឿងមួយចំនួនទៀតដែលទាក់ទងនឹងតថភាពសង្គមជាច្រើន ដែលយុវជនកម្ពុជាជំនាន់ក្រោយមានបំណងប្រាប់រឿងរ៉ាវទាំងអស់នោះនៅលើផ្ទាំងសំពត់ស ដោយការផលិតជាខ្សែភាពយន្ត ឬការចូលរួមជាមួយនឹងផលិតករភាពយន្តដទៃ។ ប៉ុន្តែ ពួកគាត់តែងតែជួបបញ្ហាជាចំបងមួយគឺ ពួកគាត់ពុំមានឱកាសទទួលការបណ្តុះបណ្តាលឲ្យបានត្រឹមត្រូវ ដើម្បីពង្រឹងទាំងចំណេះដឹង និងចំណេះធ្វើ។ ហេតុដូច្នេះហើយ មជ្ឈមណ្ឌល បានជ្រើសយកជំនាញការថតភាពយន្ត ដែលផ្តោតសំខាន់លើកការប្រើប្រាស់ម៉ាស៊ីនថតភាពយន្ត និងការប្រើពន្លឺឲ្យបានត្រឹមត្រូវតាម។

សិក្ខាកាម ២០រូប នឹងត្រូវបានជ្រើសរើសមកហ្វឹកហាត់ ទាំងទ្រឹស្តី និងការអនុវត្ត ក្នុងរយៈពេល ៣ថ្ងៃ។ អ្នកដឹកនាំភាពយន្ត អ្នកថតភាពយន្ត ការីពន្លឺ (អ្នកបច្ចេកទេសពន្លឺ) គឺត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួម។

### លក្ខខណ្ឌជ្រើសរើស

- អ្នកកំពុងធ្វើការលើវិស័យភាពយន្ត ឬអ្នកបច្ចេកទេសភាពយន្ត
- អ្នកមានបទពិសោធន៍ការងារផ្នែកជំនាញការថតភាពយន្តកាន់តែប្រសើរ
- មានពេលវេលាគ្រាប់គ្រាន់ចូលរួមវគ្គបណ្តុះបណ្តាល
- ការបណ្តុះបណ្តាលមិនតម្រូវឲ្យបង់ប្រាក់ទេ

Cambodia Film Commission, #128, rue 200, Boeung Raing, Daun Penh - Phnom Penh - Cambodia
Tél/Fax : +855 (0) 23 222 920 – (mob) +855 (0)12 817 431 - www.cambodia-cfc.org

**ការដាក់ពាក្យស្នើសុំ**

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមផ្ញើរប្រវត្តិរូបសង្ខេបឲ្យបានមុនថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៩ តាមរយៈអាស័យដ្ឋានខាងក្រោមៈ

- អ៊ីម៉ែល cinetraining@cambodia-cfc.org
- ឬ ផ្ញើមកកាន់ទំព័រ Facebook ផ្លូវការ https://www.facebook.com/contactcfc/
- ឬ មកដាក់ពាក្យនៅមជ្ឈមណ្ឌលយើងខ្ញុំផ្ទាល់ដែលមានអាស័យដ្ឋាន ផ្ទះលេខ ១២៨ ផ្លូវលេខ ២០០ ទល់មុខនាយកដ្ឋានសិល្បភាពយន្ត និងផ្សព្វផ្សាយវប្បធម៌។

សំរាប់ពត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លេខទូរសព្ទ ០២៣ ២២២ ៩២០។

*****សូមអរគុណ*****